# ខ្សែចង្វាក់តម្លៃជីនៅប្រទេសកម្ពុជា៖ ករណីសិក្សានៅខេត្តតាកែវ[១]

## សេចក្ដីផ្ដើម

ទិន្នផលស្រូវនៅប្រទេសកម្ពុជានៅតែមានកម្រិតទាប បើធៀបនឹងនៅវៀតណាម និងថៃ ដែលជាប្រទេសជិតខាង។ មូលហេតុចម្បងមួយ គឺការប្រើប្រាស់ជីមានកម្រិតទាប (Theng & Koy 2011) ទោះបីជាការសាកល្បងជាច្រើនបានបង្ហាញថា ការប្រើប្រាស់ជីនាំឲ្យស្រូវមានទិន្នផលខ្ពស់ក៏ដោយ។ ឧបសគ្គសំខាន់មួយចំពោះកំណើនការប្រើប្រាស់ធាតុចូល ទំនងជាលទ្ធភាពតូចនៃការទទួលបានស្តុកជីមានគុណភាពល្អ និងតម្លៃសមរម្យ។ ជីភាគច្រើនដែលកសិករប្រើប្រាស់ នាំចូលមកពីវៀតណាម និងថៃ ហើយបញ្ហាសំខាន់ៗទាក់ទងនឹងជីទាំងនោះរួមមានគុណភាពមានមន្ទិល ផ្លាកសញ្ញាផលិតផលមិនត្រឹមត្រូវអានមិនកើត ការផ្គត់ផ្គង់មិនអាចទុកចិត្តបាន ថ្លៃប្រែប្រួល និងព័ត៌មានមិនគ្រប់គ្រាន់ពីការប្រើប្រាស់ជី និងធាតុចូលផ្សេងទៀត។ ការសិក្សាផ្អែកលើបទពិសោធន៍ជាក់ស្ដែងដោយ Schamel and Hongen (2003) បង្ហាញថាកសិករជ្រើសរើសមិនប្រើប្រាស់ជីឬប្រើប្រាស់ជីតិចជាងកម្រិតបានណែនាំ ព្រោះកន្លងមកទីផ្សារជីធ្លាប់លក់ផលិតផលគុណភាពមិនល្អឲ្យពួកគាត់ ធ្វើឲ្យគាត់មិនចង់បង់ថ្លៃពេញសម្រាប់ជីដែលមានគុណភាពមធ្យម។ ការកំណត់ពីបញ្ហារារាំងការប្រើប្រាស់ធាតុចូលកសិកម្ម នឹងជួយបំផុសឲ្យឃើញនូវអន្តរាគមន៍គោលនយោបាយនានា ដើម្បីលើកកម្ពស់លទ្ធភាពរបស់កសិករក្នុងការទទួលបាន និងប្រើប្រាស់ធាតុចូលទាំងនោះ។

ជីអាចបង្កើនផលិតកម្មស្រូវ ប៉ុន្តែបញ្ហាផ្នែកគុណភាពធ្វើឲ្យកសិករមានការរារែកចិត្តក្នុងការវិនិយោគបន្ថែមទៅលើ ធាតុចូលកសិកម្ម។ សម្មតិកម្មនៃការសិក្សានេះ គឺលទ្ធភាពតូចក្នុងការទទួលបានជីគុណភាពល្អមានតម្លៃសមរម្យ ជាឧបសគ្គដល់ការបង្កើនទិន្នផលស្រូវ។ ការកែសម្រួលគោលនយោបាយដើម្បីដោះស្រាយសម្រាលបញ្ហានេះ អាចបង្កើនផលិតភាព និងចំណូលកសិកម្ម ដែលនឹងរួមចំណែកដល់ការលើកកម្ពស់សុខុមាលភាព និងកាត់បន្ថយភាពងាយរងគ្រោះរបស់កសិករ។ ការសិក្សានេះមានគោលបំណង៖ ១) វិភាគពីខ្សែចង្វាក់តម្លៃជីប្រើប្រាស់ក្នុងការងារកសិកម្ម ២) កំណត់ពីបញ្ហាជីមានគុណភាពទាប និងច្រកចែកចាយជីទាំងនោះ ៣) ពិនិត្យឡើងវិញពីគោលនយោបាយរដ្ឋាភិបាលក្នុងការគ្រប់គ្រងពាណិជ្ជកម្មជី និង ៤) កំណត់រកវិធីដើម្បីកែលំអទីផ្សារជី។

ករណីសិក្សានេះ ប្រើប្រាស់វិធីសាស្ត្របែបបរិមាណក្នុងការវិភាគពីខ្សែចង្វាក់តម្លៃជី ក្នុងតំបន់សិក្សានៅខេត្តតាកែវ។ ព័ត៌មានបានប្រមូលយកពីអ្នកពាក់ព័ន្ធខុសៗគ្នានៅក្នុងខ្សែចង្វាក់តម្លៃ តាមរយៈការពិភាក្សាតាមក្រុមស្នូល (FGDs) និងការសម្ភាសជាមួយអ្នកផ្ដល់ព័ត៌មានគន្លឹះ (KIIs)។ អ្នកចូលរួមផ្ដល់ព័ត៌មានរួមមាន កសិករ អ្នកនាំចូលជី អ្នកចែកចាយនិងអ្នកលក់រាយ និងអ្នកពាក់ព័ន្ធមួយចំនួនទៀត ដូចជា បុគ្គលិកផ្សព្វផ្សាយបច្ចេកទេសកសិកម្មប្រចាំខេត្ត អ្នកក្សេត្រវិទ្យានៅតាមខេត្ត និងអ្នកចូលរួមតាក់តែងច្បាប់កសិកម្មនៅតាមខេត្ត។

## លទ្ធផល និងការពិភាក្សា

### *ទីផ្សារជីនៅខេត្តតាកែវ*

ក្នុងទសវត្សរ៍កន្លងទៅ ខេត្តតាកែវបានផ្លាស់ប្ដូរយ៉ាងលឿនពីផលិតកម្មចិញ្ចឹមពោះ ទៅជាផលិតកម្មដំណាំលក់យកប្រាក់ និងសំដៅបម្រើទីផ្សារ ដែលនាំឲ្យមានកំណើនផលិតកម្មស្រូវគួរឲ្យកត់សម្គាល់។ ការផ្លាស់ប្ដូរយ៉ាងលឿននេះ បណ្ដាលមកពីការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ (ភាពមានទឹក និងការស្រោចស្រពបានប្រសើរជាងមុន) ការទទួលប្រើប្រាស់ភ្លាមៗនូវពូជស្រូវមានទិន្នផលខ្ពស់ ការប្រើប្រាស់សម្បុរឡើងនូវជីនិងថ្នាំសម្លាប់សត្វចង្រៃ និងកំណើនយន្តកម្ម។ ពាណិជ្ជកម្មឆ្លងកាត់ព្រំដែនជាមួយវៀតណាម ជាកត្តាសំខាន់មួយទៀតក្នុងការអភិវឌ្ឍដំណាំស្រូវនៅខេត្តតាកែវ។ ការលក់ស្រូវទៅឲ្យប្រទេសវៀតណាម សំខាន់ខ្លាំងណាស់ ព្រោះជាបុរេលក្ខខណ្ឌធំបំផុតសម្រាប់ការអភិវឌ្ឍកសិកម្ម និងកំណើនសេដ្ឋកិច្ច។ ស្រូវប្រាំង ជាផលិតផលនាំចេញចម្បងរបស់ខេត្តតាកែវ ហើយផលិតផលនាំចូលចម្បងៗពីវៀតណាមរួមមាន គ្រាប់ពូជ ជី និងថ្នាំសម្លាប់សត្វចង្រៃ។

ការទទួលប្រើប្រាស់ភ្លាមៗនូវពូជស្រូវផ្ដល់ទិន្នផលខ្ពស់ នាំឲ្យមានការប្រើជី និងថ្នាំសម្លាប់សត្វចង្រៃច្រើនជាងមុន។ រូបភាព ១ បង្ហាញថា កសិករជាង ៨០% នៅខេត្តតាកែវ ប្រើប្រាស់ជីអសរីរាង្គ (inorganic fertilisers) លើកលែងតែកសិករក្នុងស្រុកដូនកែវ។ ចំណុចនេះបង្ហាញថា មិនមានឧបសគ្គខាងការផ្គត់ផ្គង់ជីនៅលើទីផ្សារទេ ហើយកសិករនៅក្នុងភូមិសិក្សាទាំងអស់ក៏បានបញ្ជាក់ពីស្ថានភាពនេះដែរថា មិនមានបញ្ហាក្នុងការរកបានជីឡើយ។

នៅខេត្តតាកែវ មានក្រុមហ៊ុនផ្គត់ផ្គង់ជីធំៗចំនួន ៦ ដែលចែកចាយផលិតផលកសិកម្មទៅឲ្យចាប់ពី កម្រិតអ្នកលក់ដុំក្នុងខេត្ត រហូតដល់អ្នកលក់រាយតាមទីផ្សារក្នុងភូមិ។ ក្រុមហ៊ុនហេងពេជ្រឆាយ (HPC) មានទីស្នាក់ការ និងឃ្លាំងស្តុកទំនិញក្នុងខេត្តតាកែវ រីឯអ្នកផ្គត់ផ្គង់ប្រាំក្រុមហ៊ុនទៀត មានទីស្នាក់ការនៅក្រុងភ្នំពេញ ឬនៅកន្លែងផ្សេង ប៉ុន្តែមានកន្លែងចែកចាយក្នុងខេត្តតាកែវ បើទោះជាគេគ្មានការិយាល័យសាខានៅទីនោះក្ដី។ ក្រុមហ៊ុនផ្គត់ផ្គង់ជីធំៗពីរ គឺ YITAK Group និង HPC មានដាក់ផលិតផលនៅស្ទើរគ្រប់កន្លែងលក់ដុំ និងលក់រាយ សូម្បីតែនៅតាមហាងតូចៗក្នុងភូមិក្ដី។

---

[១] អត្ថបទនេះរៀបរៀងដោយលោក ថេង វុទ្ធី ជាអ្នកសម្របសម្រួលកម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ នៃវិទ្យាស្ថាន CDRI។ អត្ថបទនេះដកស្រង់ពីករណីសិក្សាខ្សែចង្វាក់តម្លៃជីនៃគម្រោង ACIAR (ASEM/2009/023) ស្ដីពី "ការអភិវឌ្ឍគោលនយោបាយកសិកម្ម សម្រាប់ប្រព័ន្ធដាំដុះផ្អែកលើដំណាំស្រូវ នៅឡាវ និងកម្ពុជា" ដែលគ្រោងចប់សព្វគ្រប់ នៅខែឧសភា ២០១៤។

រូបភាព ១៖ ភាគរយនៃគ្រួសារប្រើប្រាស់ជីគីមី និងថ្នាំសម្លាប់សត្វចង្រៃ ក្នុងឆ្នាំ២០១០




ប្រភព៖ ទិន្នន័យឃុំ (២០១០)

សម្គាល់៖ ភាគរយ គណនាដោយយកចំនួនគ្រួសារសរុបដែលប្រើប្រាស់ធាតុគីមីកសិកម្ម ចែកនឹងចំនួនគ្រួសារសរុបក្នុងភូមិ

នៅលើទីផ្សារមានជីជាច្រើនប្រភេទ ដែលលក់ចែកចាយដោយអ្នកនាំចូល និងអ្នកចែកចាយផ្សេងៗគ្នា។ ផលិតផលជីដែលផ្ទុកសារធាតុចិញ្ចឹមតែមួយមុខ គឺមាន ជីអ៊ុយរ៉េ និងជីប៉ូតាស្យូម (muriate of potash (KCl))។ ជីដែលមានសមាសធាតុអាសូត និងប៉ូតាស្យូម (NK) មាន ឌីអាម៉ូញ៉ូមផូស្វាត (DAP) (18-46-0) និងអាម៉ូញ៉ូមផូស្វាត (16-20-0)។ ជីមានសមាសធាតុអាសូត ផូស្វ័រ និងប៉ូតាស្យូម (NPK) មានដាក់លក់លើទីផ្សារ ក្នុងកម្រិតផ្សំ 15-15-15, 16-16-8-13s និង 20-20-15។ ជីគ្រប់ប្រភេទ ដាក់លក់ក្នុងបាវទម្ងន់ ៥០គីឡូក្រាម ប៉ុន្តែកសិករអាចទិញជាគីឡូ អាស្រ័យលើប្រាក់ដែលគាត់មាន ឬតម្រូវការរបស់គាត់។

ជីភាគច្រើនដែលលក់លើទីផ្សារ មានបិទផ្លាកជាភាសាខ្មែរ លើកលែងតែជី NPK 16-16-8-13s ដែលផលិតនៅប្រទេសហ្វីលីពីន និងជីអ៊ុយរ៉េ នាំចូលពី ចិន និងវៀតណាម ប៉ុន្តែផលិតផលទាំងនេះ មានបិទតែមតូចជាភាសាខ្មែរដែរ។ មិនមានទិន្នន័យផ្លូវការ បញ្ជាក់ពីបរិមាណជីដែលបានចែកចាយ ឬលក់ក្នុងខេត្តតាកែវទេ។ ទាំងឈ្មួញ និងមន្ទីរកសិកម្មខេត្ត សុទ្ធតែមិនមានកំណត់ត្រាពីបរិមាណជីដែលបាននាំចូល ឬចែកចាយក្នុងខេត្តតាកែវ។ គេជឿថា មានការរត់ពន្ធជីក្នុងទ្រង់ទ្រាយធំ ពីវៀតណាមមកកម្ពុជា ហើយបន្ទាប់មក ដាក់លក់ចែកចាយលើទីផ្សារ។ ទំនិញគេចពន្ធ អាចសម្គាល់បានយ៉ាងងាយ ដោយសារបាវមិនមានបិទផ្លាក ឬបិទតែមអក្សរខ្មែរ។

## ច្រកចែកចាយជី និងការវិភាគពីខ្សែចង្វាក់តម្លៃ

**រចនាសម្ព័ន្ធទីផ្សារជី** កំពុងវិវត្តយ៉ាងរហ័ស ដើម្បីបំពេញតម្រូវការកសិករ និងបម្រើដល់វិស័យដំណាំស្រូវដែលកំពុងរីកលូតលាស់នៅខេត្តតាកែវ។ រចនាសម្ព័ន្ធទីផ្សារជី មានការរៀបចំយ៉ាងល្អ និងដឹកនាំដោយផ្នែកឯកជនដែលកំពុងអនុវត្តយុទ្ធសាស្ត្រទីផ្សារប្រកួតប្រជែងគ្នាខ្លាំង ហើយមានកម្រិតថ្លៃកំណត់ដោយកម្លាំងទីផ្សារ។

អ្នកនាំចូលសញ្ជាតិកម្ពុជាមានអាជ្ញាប័ណ្ណ តែងស្តុកជីក្នុងឃ្លាំងនៅជិតព្រំដែន និង/ឬ នៅក្រុងភ្នំពេញ។ ក្រុមហ៊ុន HPC មានទីស្នាក់ការកណ្តាល និងឃ្លាំងស្តុកទំនិញនៅស្រុកគិរីវង់ក្បែរព្រំដែន និងមានរថយន្តដឹកទំនិញជាច្រើនគ្រឿងសម្រាប់ដឹកជញ្ជូនជីក្នុងខេត្តតាកែវ និងទៅខេត្តឯទៀតៗ។ ក្រុមហ៊ុនប្រាំផ្សេងទៀត មិនមានស្តុកជីនៅខេត្តតាកែវទេ ប៉ុន្តែគេមានអ្នកតំណាង/ឈ្មួញ សម្រាប់ការចែកចាយក្នុងខេត្ត។ ថ្លៃដឹកជញ្ជូន ប្រែប្រួលអាស្រ័យលើចម្ងាយផ្លូវរវាងឃ្លាំងស្តុក និងកន្លែងចែកចាយ ហើយថ្លៃដឹកជញ្ជូនជាទូទៅ គឺប្រហែល 0,២៥ដុល្លារ/បាវ ក្នុងចម្ងាយ ១00គីឡូម៉ែត្រ រីឯថ្លៃលើកដាក់ជីពីរថយន្ត គឺ 0,0៥ដុល្លារ/បាវ។ អ្នកចាយចែកធំៗភាគច្រើន មានរថយន្តសម្រាប់ដឹកជញ្ជូនទៅឲ្យអ្នកលក់បន្តនៅតាមភូមិស្រុក។ ហាងលក់នៅតាមភូមិស្រុក មានទំហំតូច និងស្តុកជីបានតិច ហើយជាទូទៅបញ្ជាទិញនៅរដូវដាំដុះ (ពីខែឧសភា ដល់កញ្ញា នៅរដូវវស្សា និង ពីខែវិច្ឆិកា ដល់ កុម្ភៈ នៅរដូវប្រាំង) ដើម្បីទុកកន្លែងដាក់ទំនិញផ្សេងទៀត។

ជាទូទៅអ្នកលក់រាយក្នុងភូមិ ជាហាងលក់ទំនិញគ្រប់មុខដែលមានលក់ធាតុចូលកសិកម្មច្រើនប្រភេទ ដូចជា ចំណីសត្វ ថ្នាំសម្លាប់សត្វចង្រៃ គ្រាប់ពូជ ប្រេងសាំង និងជី។ នៅឆ្នាំ២០១១-២០១២ មានអ្នកជំនួញប្រហែល ៦៣៤នាក់ ដែលភាគច្រើនជាម្ចាស់ហាងលក់ធាតុចូលកសិកម្ម ត្រូវបានអញ្ជើញឲ្យចូលរួមក្នុងវគ្គបណ្តុះបណ្តាល ស្តីពីសុវត្ថិភាព និងការជួញដូរផលិតផលកសិកម្ម នៅក្នុងខេត្ត។ ជាទូទៅ អ្នកលក់រាយក្នុងភូមិ ទិញជីពីអ្នកតំណាងលក់ប្រចាំខេត្ត ប៉ុន្តែមានអ្នកខ្លះទាក់ទងអ្នកផ្គត់ផ្គង់ដទៃទៀតអាស្រ័យលើថ្លៃជី និងសេវាកម្មដែលផ្តល់ឲ្យ និង/ឬ ដើម្បីបំពេញតម្រូវការអតិថិជន/កសិករ។ ការទិញលក់ធ្វើឡើងដោយយកប្រាក់ដល់ដៃ ឬតណាទាន។ ការសម្ភាសដល់កន្លែងបង្ហាញថា ការលក់រាយប្រហែលពាក់កណ្តាលធ្វើឡើងតាមឥណទាន ដោយគិតថ្លៃបន្ថែម ១៥.000 ទៅ ២0.000រៀល/បាវ ក្នុងមួយរដូវដាំដុះ (៣ ទៅ ៦ខែ)។

ការសិក្សាដល់កន្លែង បង្ហាញថា អ្នកចែកចាយចល័ត ឬឈ្មួញកណ្ដាល ជាច្រកមួយទៀតសម្រាប់ការចែកចាយធាតុចូលកសិកម្ម។ ពួកគេមិនមានការិយាល័យជំនួញជាក់លាក់ ហើយមិនដឹងថាមកពីប្រភពណាច្បាស់ទេ ប៉ុន្តែមានលេខទូរស័ព្ទទំនាក់ទំនង និងមធ្យោបាយដឹកជីនៅពេលអ្នកលក់រាយត្រូវការសេវាកម្មពីពួកគេ។ ពួកគេមានទំនាក់ទំនងរកស៊ីយ៉ាងល្អ និងយូរអង្វែងជាមួយអ្នកនាំចូលមួយចំនួន។ ពួកគេទិញជីពីអ្នកនាំចូល និងផ្ទុកវាក្នុងរថយន្តដឹកទំនិញសម្រាប់ដឹកជញ្ជូន និងលក់បន្តទៅឲ្យអ្នកលក់រាយតាមខេត្ត ស្រុក ភូមិ ឬទៅដល់កសិករផ្ទាល់។ មានការរាយការណ៍ថា ក្នុងដំណើរការនេះ អ្នកជំនួញមានឱកាសខ្ពស់ក្នុងការក្លែងបន្លំគុណភាពជី តាមការលាយជីគុណភាពទាប និងជីគុណភាពខ្ពស់ចូលគ្នា ហើយលក់ក្នុងថ្លៃស្មើជីគុណភាពខ្ពស់ ឬដោយយកជីគុណភាពទាបច្រកក្នុងបាវថ្មី ដែលបិទឈ្មោះជីគុណភាពខ្ពស់ ឬក៏លក់ជីច្រកបាវមិនគ្រប់ទម្ងន់។ ក្នុងអំឡុងពេលចុះសិក្សាដល់កន្លែង មានការរាយការណ៍ថា មានអ្នកដើរទិញបាវជីគុណភាពខ្ពស់ពីកសិករ ដូចជាបាវជីម៉ាក YITAK និង HPC ជាដើម ហើយប្រើវាសម្រាប់ធ្វើសកម្មភាពមិនត្រឹមត្រូវផ្សេងៗទៅលើជី។

**ខ្សែចង្វាក់តម្លៃជី៖** ថ្លៃដើម ថ្លៃលក់ តម្លៃលើកដាក់ តម្លៃដឹកជញ្ជូន ប្រាក់បង់ក្រៅផ្លូវការតាមផ្លូវ និងថ្លៃអប្បហារយកដោយតួអង្គផ្សេងៗក្នុងខ្សែចង្វាក់ផ្គត់ផ្គង់ជី ដែលក្រុមស្រាវជ្រាវបានកត់ត្រាក្នុងអំឡុងពេលចុះសិក្សាដល់កន្លែង ព្រមទាំងថ្លៃលក់រាយប្រចាំខែ និងប្រចាំឆ្នាំ នៃផលិតផលជីផ្សេងៗ ដែលទទួលបានពីប្រភពទិន្នន័យទី២ បានយកមកប្រើប្រាស់ក្នុងការវិភាគខ្សែចង្វាក់តម្លៃជី នៅខេត្តតាកែវ។

ការវិភាគខ្សែចង្វាក់តម្លៃបង្ហាញថាថ្លៃអប្បហារសម្រាប់ឈ្មួញដែលមិនមែនជាអ្នកនាំចូល មានកម្រិតទាប ប្រហែលជា ១,៥% ទៅ ២% ចំណែកឯថ្លៃអប្បហារសម្រាប់ក្រុមហ៊ុននាំចូល មានប្រហែល ៥% (តារាង ១)។ តួលេខនេះបង្ហាញថា ទីផ្សារជីនៅខេត្តតាកែវ មានការប្រកួតប្រជែងខ្លាំង ជាពិសេសសម្រាប់ផលិតផលប្រើទូទៅដូចជា ជីអ៊ុយរ៉េ និង DAP។ ប្រសិនបើគិតបញ្ចូលថ្លៃប្រតិបត្តិការនេះផង ឈ្មួញជីនៅខេត្ត ស្រុក និងភូមិទទួលបានអត្រាប្រាក់ចំណេញទាបណាស់។ នៅអំឡុងពេលចុះសិក្សាក្នុងខែកុម្ភៈ ២០១២ ជីអ៊ុយរ៉េ ថ្លៃប្រហែល ២៨ដុល្លារ ហើយជី DAP ថ្លៃប្រហែល ៣៦ដុល្លារ ក្នុងមួយបាវ ៥០គីឡូក្រាម។

លទ្ធផលសិក្សាបង្ហាញថា ទីផ្សារជីមានការប្រកួតប្រជែងខ្លាំងក្នុងចំណោមឈ្មួញ ដើម្បីទទួលបានចំណេញបន្តពីអ្នកនាំចូល។ តម្លៃបន្ថែមភាគច្រើនដែលកើតបន្តពីអ្នកនាំចូល គឺតម្លៃដឹកជញ្ជូនខ្ពស់ពីកន្លែងចែកចាយនៅតាមខេត្ត ទៅហាងតាមភូមិ ដែលបណ្ដាលជាចម្បងពី ការបង់ប្រាក់ក្រៅផ្លូវការច្រើនទៅឲ្យប៉ូលីសតាមផ្លូវនៅពេលដឹកជញ្ជូន។ ដូច្នេះ បើគិតបញ្ចូលតម្លៃ

តារាង ១៖ ការវិភាគខ្សែចង្វាក់តម្លៃជីអ៊ុយរ៉េ និង DAP សម្រាប់ខែ កុម្ភៈ ២០១២

| | ជីអ៊ុយរ៉េគ្រាប់ | | DAP (USA) | |
|---|---|---|---|---|
| | ដុល្លារ/៥០គីឡូ | % នៃថ្លៃចូល | ដុល្លារ/៥០គីឡូ | % នៃថ្លៃចូល |
| **ថ្លៃដើមជី១បាវនាំចូលនៅព្រំដែនវៀតណាម** | - | - | **31.5** | **100** |
| តម្លៃដឹកជញ្ជូនមកកម្ពុជា(<100km ថ្លៃ $0.25) | - | - | 0.3 | 0.8 |
| តម្លៃស្ដុក | - | - | 0.1 | 0.2 |
| **តម្លៃចូលឃ្លាំងនៅព្រំដែន** | - | - | **31.8** | **101.0** |
| ការដូរផ្លាកសញ្ញា និងអប្បហារលើការនាំចូល | - | - | 1.7 | 5.3 |
| **ថ្លៃលក់របស់អ្នកនាំចូល** | **24** | **100** | **33.5** | **106.3** |
| តម្លៃដឹកទៅតាមខេត្ត (100km ថ្លៃ $0,២៥) | 0.3 | 1.0 | 0.3 | 0.7 |
| អប្បហារគិតដោយអ្នកចែកចាយ និងតម្លៃលើកដាក់ | 0.8 | 3.1 | 0.8 | 2.2 |
| **តម្លៃចូលស្ដុករបស់អ្នកចែកចាយថ្នាក់ខេត្ត** | **25.0** | **104.1** | **34.5** | **109.3** |
| ថ្លៃអប្បហារគិតដោយអ្នកចែកចាយថ្នាក់ខេត្ត | 0.5 | 2.0 | 0.5 | 1.4 |
| **ថ្លៃលក់របស់អ្នកចែកចាយ** | 25.5 | 106.1 | 35.0 | 110.7 |
| តម្លៃដឹកជញ្ជូនទៅឲ្យអ្នកលក់នៅតាមភូមិ និងលើកដាក់ | - | - | 1.0 | 2.9 |
| តម្លៃចូលស្ដុករបស់អ្នកលក់នៅតាមភូមិ | - | - | 36.0 | 113.6 |
| ថ្លៃអប្បហាររបស់អ្នកលក់បន្តសម្រាប់ការលក់យកប្រាក់ដល់ដៃ | 3.3 | 12.7 | 0.5 | 1.4 |
| **ថ្លៃលក់រាយយកប្រាក់ដល់ដៃ** | **28.8** | **118.9** | **36.5** | **115.0** |

ប្រភព៖ ការគណនារបស់អ្នកនិពន្ធដោយផ្អែកលើទិន្នន័យបានពីសម្ភាសន៍ដល់កន្លែង ក្នុងខែកុម្ភៈ ២០១២

ប្រតិបត្តិការ និងតម្លៃផ្នែកផ្គត់ផ្គង់ ( logistics ) នេះផង ឈ្មួញលក់ជីភាគច្រើននៅខេត្តតាកែវ មិនអាចបង្កើតប្រាក់ចំណេញបានច្រើនទេ។ តម្លៃបន្ថែមកម្រិតខ្ពស់នៃជី រួមមាន ថ្លៃអប្បហាររបស់អ្នកនាំចូល (៥%) និងតម្លៃផ្គត់ផ្គង់ (៣%)។ លទ្ធផលសិក្សានេះមានលក្ខណៈស្របគ្នាជាមួយនឹងការសិក្សារបស់ មជ្ឈមណ្ឌលអភិវឌ្ឍន៍ជីអន្តរជាតិ ( IFDC 2010 )។

## *បញ្ហាផ្សេងៗនៃទីផ្សារជី - តើផលិតផលក្លែងក្លាយត្រូវបានចែកចាយយ៉ាងដូចម្តេច?*

បញ្ហាគុណភាពជី បានកើតមាន ដោយសារថ្លៃជីស្ទុះឡើងយ៉ាងគំហុកក្នុងឆ្នាំ២០០៨ ដែលបង្កើតនូវឱកាសសម្រាប់ការអនុវត្តមិនត្រឹមត្រូវក្នុងវិស័យនេះ ដើម្បីឆ្លើយតបនឹងតម្រូវការរបស់កសិករនូវជីមានតម្លៃថោកៗ។ IFDC (2010) បានរកឃើញថា ការវិភាគរកជីវជាតិក្នុងជីសមាស NPK និង NP ស្ទើរតែគ្រប់ប្រភេទដែលលក់លើទីផ្សារ បង្ហាញថា វាមានកម្រិតទាបខ្លាំងជាងតម្លៃសន្ទស្សន៍គុណភាពដែលអាចទទួលយកបាន។ ទោះយ៉ាងណាក្តី ការវិភាគបង្ហាញថា បរិមាណជីវជាតិក្នុងជីឯកធាតុ (អ៊ុយរ៉េ និង DAP ខ្លះ) ស្ថិតក្នុងកម្រិតស្តង់ដាអាចទទួលយកបាន (IFDC 2010: 25-35 )។

បញ្ហាគុណភាពដែលកើតមានទូទៅជាងគេគឺ ជីក្លែងក្លាយ។ ក្នុងអំឡុងពេលចុះសិក្សា និងចុះសម្ភាសដល់កន្លែង អ្នកប្រើប្រាស់ អ្នកនាំចូល អ្នកចែកចាយ និងមន្ត្រីជាន់ខ្ពស់នៃមន្ទីរកសិកម្មខេត្ត បានរាយការណ៍ថា ផលិតផលក្លែងក្លែងឃើញមាននៅស្ទើរគ្រប់កន្លែង។ បញ្ហានេះមិនមែនជារឿងថ្មីទេ ហើយវាមានលក្ខណៈស្រដៀងគ្នានឹងលទ្ធផលសិក្សារបស់ IFDC (2010) ដែរ។ ការអនុវត្តទូទៅបំផុត គឺការវេចខ្ចប់ឡើងវិញ នូវជីមានតម្លៃថោកជាងដូចជា ជី DAP និងជីអ៊ុយរ៉េ ក្នុងបាវមានផ្លាកសញ្ញាជីគុណភាពខ្ពស់ ដូចជា ជីអ៊ុយរ៉េ មកពីថៃ និង ជី DAP ផលិតនៅ USA ដែលគេស្គាល់ថាជាផលិតផលមានគុណភាពខ្ពស់។ ដូច្នេះហើយ ឈ្មួញមួយចំនួនបានវេចខ្ចប់ឡើងវិញនូវជីមានគុណភាពទាប ដោយប្រើបាវជីមានគុណភាពខ្ពស់ រួចបញ្ចេញលក់ទៅឲ្យអតិថិជន។

បញ្ហាការបន្លំលាយជីនឹងសារធាតុផ្សេងទៀត ក៏មានរាយការណ៍ដោយកសិករអ្នកឆ្លើយសម្ភាសន៍ដែរ។ កសិករ ប្រាប់ថា ដំណាំរបស់គាត់ មិនសូវឲ្យផលល្អជាមួយជីនេះ ដូចកាលពីឆ្នាំមុនទេ ហើយបានបន្ទោសថាបញ្ហានេះកើតឡើងដោយសារជីមានគុណភាពទាប។ ទោះយ៉ាងណាក្តី អ្នកជំនាញការបច្ចេកទេសបានវែកញែកថា បញ្ហានេះមិនអាចបន្ទោសទៅលើគុណភាពជីតែមួយមុខទេ ព្រោះកត្តាផ្សេងទៀត ដូចជា លក្ខខណ្ឌរដូវខុសគ្នា គុណភាពគ្រាប់ពូជ និងរបៀបដាំដុះជាដើម ក៏ប៉ះពាល់ទៅលើទិន្នផលដែរ។ ទោះបី អ្នកជំនាញការបានវែកញែកដូច្នេះក្តី ក៏លទ្ធផលបានពីការសម្ភាសជាមួយកសិករ អ្នកចែកចាយ អ្នកនាំចូលជី និងការវិភាគពីជីវជាតិក្នុងជី ដោយ IFDC (2010) នៅតែបង្ហាញថា ជីមានគុណភាពទាបលក់នៅទីផ្សារ ជាបញ្ហាធ្ងន់ធ្ងរដែលជះឥទ្ធិពលដល់ផលដំណាំ និងបណ្តាលឲ្យកសិករក្នុងតំបន់សិក្សាត្រូវខាតបង់ប្រាក់កាស។

ការលក់ជីមិនគ្រប់ទម្ងន់ និង ជី NKP មានគុណភាពទាបដែលគេបានលាយជាតិប្រេងដើម្បីផ្លាស់ប្តូរពណ៌ជីនោះ ក៏មានរាយការណ៍ឡើងដោយកសិករ និងអ្នកចែកចាយ ក្នុងអំឡុងពេលចុះសិក្សាដល់កន្លែងដែរ។ ប៉ុន្តែបញ្ហានេះ កើតមានឡើងក្នុងឆ្នាំ២០០៨ ហើយបច្ចុប្បន្ននេះមិនសូវមានទេ។ កសិករបានបញ្ជាក់ថា បញ្ហាដែលកើតមានទូទៅជាងគេ គឺការច្រកបាវឡើងវិញ និងការលាយបន្លំ។ មន្ត្រីជាន់ខ្ពស់នៃមន្ទីរកសិកម្មខេត្ត អ្នកចែកចាយ និងអ្នកលក់រាយបានរាយការណ៍ពីការថយចុះគួរឲ្យកត់សម្គាល់នូវផលិតផលក្លែងក្លាយ ប៉ុន្តែបញ្ហានេះនៅតែប៉ះពាល់ដល់ប្រហែលពី ៥ ទៅ ១០% នៃជីដាក់លក់នៅទីផ្សារ។

រូបភាព ២ ពិពណ៌នាពី ច្រកបែងចែកផលិតផលក្លែងក្លាយដែលអាចកើតមាន។ មន្ត្រីជាន់ខ្ពស់តែងច្បាប់ខាងកសិកម្ម និងអ្នកនាំចូលជី ជឿជាក់ថា អ្នកចែកចាយ និងអ្នកលក់រាយភាគច្រើនមិនបានចែកចាយជីក្លែងក្លាយទៅឲ្យអតិថិជនទេ។ ប៉ុន្តែពួកគេបានចោទការចែកចាយជីមានបញ្ហា ទៅលើអ្នកលក់រាយតូចតាច ឈ្មួញកណ្តាល និងអ្នកចែកចាយចល័ត។ កិច្ចប្រឹងប្រែងរួមគ្នារបស់ក្រសួងកសិកម្ម និងមន្ទីរកសិកម្មខេត្ត ដើម្បីចាត់វិធានការបំបាត់បញ្ហាជី មានឥទ្ធិពលតិចតួចណាស់ ដោយសារមិនមានបទបញ្ញត្តិគ្រប់គ្រាន់ និងការត្រួតពិនិត្យអ្នកចែកចាយឲ្យបានត្រឹមត្រូវ។ អ្នកលក់ជីទាំងនេះ យ៉ាងហោចណាស់ក៏គួរតែត្រូវបានចុះបញ្ជីដែរ ដើម្បីអាចតាមដានត្រួតពិនិត្យសកម្មភាពជំនួញរបស់ពួកគេ និងកាត់បន្ថយជាអតិបរមានូវបញ្ហាក្លែងបន្លំលាយជី។

## *គោលនយោបាយរដ្ឋាភិបាលលើទីផ្សារជី*

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរទទួលខុសត្រូវលើការគ្រប់គ្រងពាណិជ្ជកម្មជីនៅកម្ពុជា។ ការនាំចូលផលិតផលគីមីកសិកម្ម ដូចជា ជី និងថ្នាំសម្លាប់សត្វចង្រៃ ត្រូវមានអាជ្ញាប័ណ្ណ ដែលអ្នកនាំចូលត្រូវសុំសាជាថ្មីជារៀងរាល់ឆ្នាំ។ ដើម្បីដាក់ពាក្យសុំអាជ្ញាប័ណ្ណ អ្នកនាំចូលត្រូវផ្តល់ព័ត៌មានលំអិតអំពីផលិតផល និងបរិមាណដែលត្រូវនាំចូល ព្រមទាំងលទ្ធផលវិភាគពីមន្ទីរពិសោធន៍លើផលិតផលនោះ ដើម្បីបញ្ជាក់ពីគុណភាព។ ពាក្យសុំនីមួយៗមិនថាសម្រាប់ជីឯកធាតុឬជីសមាស មានការកំណត់បរិមាណនាំចូលអតិបរមាត្រឹម ៣០.០០០តោន។

អ្នកជំនាញការខាងកសិអាជីវកម្ម បានវែកញែកថា នីតិវិធីផ្តល់អាជ្ញាប័ណ្ណនាំចូលមានភាពស្មុគស្មាញ មិនអាចបំពេញតាមតម្រូវការទីផ្សារ និងដាក់កំហិតលើការប្រកួតប្រជែងនៅទីផ្សារ។ នីតិវិធីនេះ បង្កើតជាឱកាសរកកម្រៃក្រៅផ្លូវការ គឺមានការបង់ប្រាក់ក្រៅផ្លូវការជាច្រើនទៅឲ្យអ្នកសម្របសម្រួល ដើម្បីទទួលបានការចេញអាជ្ញាប័ណ្ណឲ្យ។ ម្យ៉ាងទៀត ការរឹតត្បិតបរិមាណនាំចូលសម្រាប់អ្នកនាំចូលម្នាក់ៗ វាផ្ទុយពីគោលការណ៍ទីផ្សារ ដោយវារារាំងដល់ការកាត់បន្ថយបន្ទុកចំណាយតាមការពង្រីកទំហំអាជីវកម្មរបស់អ្នកនាំចូល។ នៅគ្រប់សេដ្ឋកិច្ចបែបទីផ្សារ វិស័យឯកជន គួរមានសេរីភាពកំណត់ការផ្គត់ផ្គង់ដោយផ្អែកលើការវាយតម្លៃស្ថានភាពទីផ្សារ និងពាណិជ្ជកម្ម។ តួនាទីរបស់រដ្ឋាភិបាល គួរផ្តោតលើការត្រួតពិនិត្យគុណភាព ដោយផ្អែកលើច្បាប់ផ្លាកសញ្ញាផលិតផល។ ប្រព័ន្ធអាជ្ញាប័ណ្ណ និងកូតា ក៏ជា

រូបភាព ២៖ ច្រកចែកចាយជីក្នុងខេត្តតាកែវ




សម្គាល់៖ លំហូរជីមានគុណភាព ——→; លំហូរជីអាចមានការក្លែងក្លាយ - - - - - →

កត្តាជំរុញឲ្យមានការនាំចូលខុសច្បាប់ និងរារាំងក្រុមហ៊ុនតូចៗមិនឲ្យចូលប្រឡូកទីផ្សារបាន។

ដើម្បីឆ្លើយតបនឹងបញ្ហាជីដែលកើតមានយ៉ាងច្រើនចាប់តាំងពីឆ្នាំ២០០៨ មក និងដោះស្រាយបញ្ហាទំនិញក្លែងក្លាយ ក្រសួងកសិកម្ម និងការិយាល័យនីតិកម្មកសិកម្ម នៃមន្ទីរកសិកម្មខេត្ត បានដាក់ចេញនូវវិធានការគោលនយោបាយបន្ទាន់ជាច្រើន លើបញ្ហាដូចជា ការចេញលិខិតអនុញ្ញាតសម្រាប់អ្នកលក់រាយ និងអ្នកចែកចាយជី ការបណ្តុះបណ្តាលដល់អ្នកលក់ដុំ អ្នកលក់រាយ និងកសិករ ពីរបៀបសម្គាល់ជីក្លែងក្លាយ ជីលាយបន្លំ និងជីច្រកបាវឡើងវិញ ការប្រកួតប្រជែងក្នុងចំណោមអ្នកនាំចូលជីចម្បងៗ ដើម្បីបានចំណែកទីផ្សារនៅក្នុងទីផ្សារសរុបមួយមានទំហំតូច និងការអនុម័តច្បាប់ថ្មីមួយនៅចុងឆ្នាំ២០១១ ដើម្បីកំណត់លើការចុះបញ្ជីអាជីវកម្ម ពាណិជ្ជកម្ម និងការប្រើប្រាស់ផលិតផលគីមីកសិកម្មក្នុងប្រទេសកម្ពុជា។

## ភាពជំពាក់ទាក់ទងផ្នែកគោលនយោបាយ

ភស្តុតាងទទួលបានពីការសិក្សាដល់កន្លែងបង្ហាញថា ទីផ្សារជីអាចធ្វើការកែលំអបាន មិនត្រឹមតែក្នុងខេត្តតាកែវប៉ុណ្ណោះទេ ប៉ុន្តែក្នុងប្រទេសកម្ពុជាទាំងមូល តាមរយៈដំណោះស្រាយមួយចំនួនដូចខាងក្រោម៖

១. ការធ្វើឲ្យសាមញ្ញងាយស្រួលនូវបទបញ្ញត្តិ និងនីតិវិធីផ្តល់អាជ្ញាប័ណ្ណនាំចូលជី ដើម្បីព្យាយាមលុបបំបាត់ឱកាសរកកម្រៃក្រៅផ្លូវការ និងកាត់បន្ថយការនាំចូលខុសច្បាប់។

២. អាជ្ញាប័ណ្ណនាំចូល គួរអនុម័តចេញឲ្យដោយផ្អែកលើភាពសមស្របនៃការប្រើប្រាស់ផលិតផលនោះ នៅក្នុងប្រទេសកម្ពុជា ហើយគួរអនុញ្ញាតឲ្យអ្នកនាំចូលអាចធ្វើការនាំចូលជីដែលបានចុះបញ្ជីរួច ក្នុងបរិមាណផ្អែកតាមតម្រូវការទីផ្សារ និងហានិភ័យទីផ្សារដែលវិស័យឯកជនបានវាយតម្លៃឃើញ។

៣. ក្រៅពីការចេញលិខិតអនុញ្ញាតសម្រាប់ អ្នកចែកចាយ និងអ្នកលក់រាយ វាដល់ពេលដែលក្រសួងកសិកម្ម និងការិយាល័យនីតិកម្មកសិកម្មខេត្ត គួរអនុវត្តជំហានបន្តក្នុងការចេញលិខិតអនុញ្ញាតឲ្យឈ្មួញ ដែលជាភាគីទី៣ (អន្តរការី អ្នកចែកចាយចល័ត អ្នកលក់រាយក្នុងភូមិតាមរដូវកាល) ដើម្បីធ្វើការទិញ និងដឹកជញ្ជូនជីទៅភូមិសម្រាប់លក់បន្តទៅឲ្យកសិករ។

## ឯកសារយោង

Agricultural Marketing Office (2002–2010), Agricultural Marketing Information Bulletin 2002–2010 (Phnom Penh: Department of Planning and Statistics, Ministry of Agriculture, Forestry and Fisheries)

International Fertiliser Development Centre (2010), *Rapid Appraisal of Fertiliser Quality in Cambodia*, IFDC report prepared for the World Bank

Schamel, G. & F. Hongen (2003), “Adverse Selection in Developing Country Factor Markets: The Case of Fertiliser in Cambodia”, paper prepared for the 2003 AAEA Annual Meeting held in Montreal, Canada, 27-30 July 2003

Theng V. & Koy R. (2011), *Review of Agricultural Policy and Policy Research*, Policy Discussion Paper (Phnom Penh: CDRI)